**Declassified to Public**
**05 May 2021**

លេខ៖ D368

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| |
|---|
| **ឯកសារដើម** |
| ORIGINAL DOCUMENT/DOCUMENT ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 09 / 2017 |
| ម៉ោង (Time/Heure) : 10 : 30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA |

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧**

ភាសា ៖ **ខ្មែរ/អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ
Neville SORAB

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

I. **ប្រវត្តិនីតិវិធី**

១. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បាន ចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ យើងបានជូនដំណឹងភាគីអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ហើយបានជូនដំណឹងភាគីថា ភាគីមានរយៈពេល ១៥ ថ្ងៃដើម្បីសុំឱ្យមានកិច្ចស៊ើប សួរបន្ថែម[1]។

៣. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ មេធាវីការពារក្តី យឹម ទិត្យ ("មេធាវីការពារក្តី") បាន ដាក់សំណើសុំពន្យារពេលរយៈពេល ១៥ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែមនេះយ៉ាង ហោចណាស់ឱ្យបាន ៦ ខែ ("សំណើសុំពន្យារពេល")[2]។

៤. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ សំណើសុំការបញ្ជាក់អំពីដីកាសម្រេចរបស់ ស.ច.ស.អន្តរជាតិ លើសំណើរបស់ ស.ព.អ សុំ បំពេញកិច្ចស៊ើបសួរទាក់ទងនឹងរបាយការណ៍វិភាគរបស់ វឿន វុទ្ធី ជាអ្នកជំនាញអង្គវិជ្ជាដែល បានរៀបចំរបាយការណ៍គាស់រណ្តៅសាកសពនៅទីតាំងឧក្រិដ្ឋកម្មមួយចំនួន ហើយបានផ្តល់ សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ អំពីបញ្ហាទាំងនេះ("សំណើសុំការបញ្ជាក់")[3]។ ជាពិសេស ស.ព.អ បានស្នើសុំ ស.ច.ស បញ្ជាក់ជាមួយ វឿន វុទ្ធី ថាតើរបាយការណ៍មួយក្នុងចំណោម របាយការណ៍របស់គាត់គឺពាក់ព័ន្ធនឹងមន្ទីរសន្តិសុខវត្តប្រធាតុដែរឬអត់ ហើយប្រសិនបើពាក់ ព័ន្ធ ស្នើសុំ ស.ច.ស ដាក់របាយការណ៍នោះចូលក្នុងសំណុំរឿង។

៥. នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ យើងបានចេញដីកាសម្រេចលើសំណើសុំពន្យារពេល ដោយបដិសេធសំណើសុំពន្យារពេលដល់ ៦ ខែ ប៉ុន្តែ យើងបានអនុញ្ញាតផ្តល់ជូនភាគីនូវរយៈ ពេល ៣០ ថ្ងៃបន្ថែមវិញ មានន័យថា រហូតដល់ថ្ងៃ ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ភាគីអាចស្នើ

---

[1] សំណុំរឿង ០០៤ ឯកសារ D358 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[2] សំណុំរឿង ០០៤ ឯកសារ D361 *សំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧។

[3] សំណុំរឿង ០០៤ ឯកសារ D338/2 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបញ្ជាក់អំពីដីកាសម្រេចលើកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។



CO. INVESTIGA... E.C.C...

01530428



សុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ("ដីកាសម្រេចលើការពន្យារពេល")[4]។ នៅថ្ងៃដដែលនេះ មេធាវីការពារក្តី បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារពេល[5]។

៦. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់សំណើសុំព្យួរការអនុវត្តកាលកំណត់ឱ្យភាគីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដោយសារថា មេធាវីការពារក្តី ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារពេល[6]។

៧. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានចេញសេចក្តីសម្រេចបដិសេធសំណើសុំព្យួរការអនុវត្តកាលកំណត់របស់មេធាវីការពារក្តី[7]។

៨. នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.អន្តរជាតិ លើសំណើដែល ស.ព.អ បានដាក់នៅខែ មីនា ឆ្នាំ ២០១៧ សុំដាក់ផែនទី និងឯកសារមួយចំនួនពីសំណុំរឿង ០០២ និង ០០៣ ចូលក្នុងសំណុំរឿង ០០៤[8]។ នៅត្រឹមថ្ងៃចេញសេចក្តីជូនដំណឹងនេះ អ.ប.ជ នៅពិនិត្យបណ្តឹងឧទ្ធរណ៍នេះ។

៩. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើដោយយោងលើរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងក្រាំងតាចាន់នៅក្នុងសំណុំរឿង ០០៤ ហើយស្នើសុំឱ្យយើងដាក់ឧបសម្ព័ន្ធនៃរបាយការណ៍នោះចូលក្នុងសំណុំរឿង ("សំណើក្រាំងតាចាន់")[9]។

---

[4]សំណុំរឿង ០០៤ ឯកសារ D361/4 *ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧។

[5]សំណុំរឿង ០០៤ ឯកសារ D361/4/1 *សៀវភៅចុះបញ្ជីបណ្តឹងឧទ្ធរណ៍អំពីសេចក្តីជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់* ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧។

[6]សំណុំរឿង ០០៤ ឯកសារ D361/4/1/1 *សំណើសុំរបស់ យឹម ទិត្យ សុំព្យួរការអនុវត្តកាលកំណត់ក្នុងដីកាសម្រេច D361/4 ដោយរង់ចាំសេចក្តីសម្រេចនៃនីតិវិធីបណ្តឹងឧទ្ធរណ៍* ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧។

[7]សំណុំរឿង ០០៤ ឯកសារ D361/4/1/3 *សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំព្យួរការអនុវត្តកាលកំណត់ដីកាសម្រេច D361/4 ដោយរង់ចាំសេចក្តីសម្រេចនៃនីតិវិធីបណ្តឹងឧទ្ធរណ៍* ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧។

[8]សំណុំរឿង ០០៤ ឯកសារ D347/2/1/2 *បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ឯកសារចូលក្នុងសំណុំរឿង ០០៤* ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧។

[9]សំណុំរឿង ០០៤ ឯកសារ D363 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ឧបសម្ព័ន្ធភ្ជាប់ទៅនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្មក្រាំងតាចាន់ ទៅក្នុងសំណុំរឿង ០០៤* ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧។

១០. នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើសុំដាក់ចូលក្នុងសំណុំរឿងនូវសក្ខីកម្មសំណុំរឿង ០០២ ទាំងស្រុងពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលសក្ខីកម្មខ្លះរបស់ពួកគាត់មាននៅក្នុងសំណុំរឿង ០០៤ រួចហើយ ("សំណើសុំសក្ខីកម្មសំណុំរឿង ០០២")[10]។

១១. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចលើសំណើក្រាំងតាចាន់ ដោយបង្គាប់ឲ្យដាក់ចូលក្នុងសំណុំរឿងនូវឧបសម្ព័ន្ធនៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងក្រាំងតាចាន់[11]។

១២. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារពេល[12]។ នៅត្រឹមថ្ងៃចេញសេចក្តីជូនដំណឹងនេះ អ.ប.ជ នៅពិនិត្យបណ្តឹងឧទ្ធរណ៍នេះ។

១៣. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើចំនួនពីរសុំបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៤៖ សំណើទី ១ សុំបំពេញកិច្ចស៊ើបសួរមួយចំនួន រួមមានការដាក់ឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសំណើនេះចូលក្នុងសំណុំរឿង ("សំណើសុំបំពេញកិច្ចស៊ើបសួរទី ១ របស់ ស.ព.អ")[13] ហើយសំណើទី ២ សុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងគុកលេខ ៨ នៅស្រុកកណ្តៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន (សំណើសុំបំពេញកិច្ចស៊ើបសួរទី ២ របស់ ស.ព.អ)[14]។

---

[10]សំណុំរឿង ០០៤ ឯកសារ D364 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ទៅក្នុងសំណុំរឿងនូវសវនាការទាំងមូលនៃសំណុំរឿង ០០២ របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលសក្ខីកម្មមួយផ្នែករបស់ពួកគាត់មាននៅក្នុងសំណុំរឿងរួចហើយ* ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧។

[11]សំណុំរឿង ០០៤ ឯកសារ D363/1 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ឧបសម្ព័ន្ធភ្ជាប់ទៅនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្មក្រាំងតាចាន់ទៅក្នុងសំណុំរឿង ០០៤* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧។

[12]សំណុំរឿង ០០៤ ឯកសារ D361/4/1/5 *បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំឲ្យបានគ្រប់គ្រាន់* ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៧។

[13]សំណុំរឿង ០០៤ ឯកសារ D366 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ អមដោយឧបសម្ព័ន្ធ ក* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧។

[14]សំណុំរឿង ០០៤ ឯកសារ D365 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ៨ នៅស្រុកកណ្តៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន ខេត្តពោធិ៍សាត់* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧។

១៤. នៅថ្ងៃដដែលនេះ មេធាវីការពារក្តី បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដោយស្នើសុំព័ត៌មានទាក់ទងនឹងការដែលអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")អាចប្រើប្រាស់តារាងអង្គការលេខដែលទទួលបានដោយសារពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅពេលដែលស្តាប់ចម្លើយសាក្សីសំណុំរឿង ០០៤ ("សំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី")[15]។

១៥. នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចផ្នែកខ្លះលើសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ របស់ ស.ព.អ ដោយបដិសេធសំណើលើផ្នែកដែលស្នើសុំឱ្យដាក់ចូលក្នុងសំណុំរឿងនូវបញ្ជីឈ្មោះរបស់ ក.ស.ច.ស អំពីមនុស្សដែលបានជាប់ឃុំ និងត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស ២១ និងឯកសារមូលដ្ឋានទាំងនោះ ហើយនៅតែពិនិត្យសំណើចំពោះផ្នែកផ្សេងទៀតទាំងអស់[16]។

១៦. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចលើសំណើសុំការបញ្ជាក់ ដោយជូនដំណឹង ស.ព.អ អំពីកិច្ចខិតខំប្រឹងប្រែងរបស់ ក.ស.ច.ស ដើម្បីទទួលឱ្យបាននូវព័ត៌មានពី វឿន វុទ្ធី ទាក់ទងនឹងរបាយការណ៍គាស់រណ្តៅសាកសពនៅមន្ទីរសន្តិសុខវត្តប្រធាតុ ហើយក៏បានបដិសេធសំណើរបស់ ស.ព.អ ដែលស្នើសុំដាក់របាយការណ៍នេះចូលក្នុងសំណុំរឿង[17]។

១៧. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចលើសំណើសត្តិកម្មសំណុំរឿង ០០២ ដោយអនុញ្ញាតតាមសំណើ ហើយបង្គាប់ឱ្យក្រឡាបញ្ជីដាក់ប្រតិចារឹកចំនួន ៥ ចូលក្នុងសំណុំរឿង[18]។

---

[15]សំណុំរឿង ០០៤ ឯកសារ D367 *សំណើរបស់ យឹម ទិត្យ សុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការប្រើប្រាស់តារាងអង្គការលេខដែលទទួលបានដោយសារពាក់ព័ន្ធនឹងការធ្វើទារុណកម្ម* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧។

[16]សំណុំរឿង ០០៤ ឯកសារ D366/1 *ដីកាសម្រេចទី ១ ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ(D366)* ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៧។

[17]សំណុំរឿង ០០៤ ឯកសារ D338/3 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបញ្ជាក់អំពីដីកាសម្រេចលើកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧។

[18]សំណុំរឿង ០០៤ ឯកសារ D364/2 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ប្រតិចារឹកទាំងស្រុងចូលក្នុងសំណុំរឿង* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧។

01530431



១៨. នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ យើង បានចេញដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី ដោយបញ្ជាក់ថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានប្រើប្រាស់តារាងអង្គការលេខដែលទទួលបានដោយសារពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅពេលដែលស្តាប់ចម្លើយសាក្សីសំណុំរឿង ០០៤ ទេ[19]។

១៩. នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចលើផ្នែកផ្សេងទៀតទាំងអស់នៃសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ របស់ ស.ព.អ ដោយក្នុងដីកាសម្រេចនេះគាត់បានបង្ហាញពីវិធានការដែល ក.ស.ច.ស បានធ្វើឡើងជាការឆ្លើយតបទៅនឹងផ្នែកនានានៃសំណើ បានអនុញ្ញាតតាមសំណើលើផ្នែកដែលស្នើសុំដាក់ប្រតិចារិកសំណុំរឿង ០០២ មួយចំនួនចូលក្នុងសំណុំរឿង ហើយបានបដិសេធផ្នែកផ្សេងទៀតទាំងអស់នៃសំណើ[20]។

២០. នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរទី ២ របស់ ស.ព.អ[21]។

## II. ពិភាក្សា

២១. វិធានផ្ទៃក្នុង ៦៦(១) តម្រូវថា បន្ទាប់ពីចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ភាគីទាំងអស់ត្រូវមានរយៈពេល ១៥ ថ្ងៃ ដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម។ វិធានផ្ទៃក្នុងមិនផ្តល់សិទ្ធិឱ្យភាគីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតទេបន្ទាប់ពី ក.ស.ច.ស បានបំពេញកិច្ចស៊ើបសួរយោងតាមសំណើដែលបានដាក់នៅក្នុងរយៈពេល ១៥ ថ្ងៃនេះ។ ការផ្តល់ពេលវេលាបន្ថែមទៀតបន្ទាប់ពីដាក់សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរនេះ គឺជាវិធានការពិសេសដែលស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់ ស.ច.ស អាស្រ័យជាចម្បងលើចំនួន

---

[19]សំណុំរឿង ០០៤ ឯកសារ D367/1 *ដីកាសម្រេចលើសំណើ យឹម ទិត្យ សុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការប្រើប្រាស់តារាងអង្គការលេខដែលទទួលបានដោយសារពាក់ព័ន្ធនឹងការធ្វើទារុណកម្ម* ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧។

[20]សំណុំរឿង ០០៤ ឯកសារ D366/4 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ អមដោយឧបសម្ព័ន្ធ ក* ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧។

[21]សំណុំរឿង ០០៤ ឯកសារ D365/3 *ដីកាសម្រេចទី ២ លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ ៨ នៅស្រុកល្វៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន* ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧។

និងគុណភាពភ័ស្តុតាងដែលប្រមូលបានបន្ទាប់ពីចេញសេចក្តីជូនដំណឹងលើកទី ១ អំពីការបិទកិច្ចស៊ើបសួរ[22]។

២២. បន្ទាប់ពីមានសំណើសុំការបញ្ជាក់មក នៅថ្ងៃទី ២០ និង ២១ ខែ កក្កដា ឆ្នាំ ២០១៧ អ្នកស៊ើបអង្កេត និងអ្នកវិភាគនៅ ក.ស.ច.ស បានទាក់ទង វឿន វុទ្ធី ដើម្បីបញ្ជាក់ថាតើគាត់បានរៀបចំរបាយការណ៍វិភាគសាកសពនៅមន្ទីរសន្តិសុខវត្តប្រធាតុដែរឬអត់ និង បញ្ជាក់ពីវិធីសាស្ត្រដែលគាត់បានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍នោះ។ វឿន វុទ្ធី បានផ្តល់ព័ត៌មានខ្លះនៅក្នុងការពិភាក្សាគ្នានេះ ប៉ុន្តែ បន្ទាប់មក គាត់មិនបានឆ្លើយតបទៅនឹងការទាក់ទងរបស់ ក.ស.ច.ស ដើម្បីទទួលបានរបាយការណ៍នោះទេ[23]។ ដោយពិនិត្យមើលព័ត៌មានដែលទទួលបានពី វឿន វុទ្ធី កង្វះកិច្ចសហការពីគាត់ និងមន្ទិលសង្ស័យរបស់ ស.ច.ស.អន្តរជាតិទៅលើភាពអាចទុកចិត្តបាន និង តម្លៃភ័ស្តុតាងទាបនៃរបាយការណ៍នោះ ទើបមិនមានកិច្ចស៊ើបសួរថែមទៀតទេ ហើយ ស.ច.ស.អន្តរជាតិ ក៏មិនបានបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរថែមទៀតជាការឆ្លើយតបទៅនឹងសំណើសុំការបញ្ជាក់ដែរ[24]។

២៣. បន្ទាប់ពីមានសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ របស់ ស.ព.អ មក អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានទាក់ទងសាក្សីមួយចំនួនដើម្បីបញ្ជាក់ពីទីកន្លែងរបស់ ខៀវ សារិន និង យាយ ខឿន ជាសាក្សីពីរនាក់ដែល ស.ព.អ បានបញ្ជាក់ថា ជាបឋមពាក់ព័ន្ធជាមួយនឹងបទចោទលើ យឹម ទិត្យ នៅស្រុកគិរីវង់ និងមន្ទីរសន្តិសុខវត្តប្រធាតុ។ ការស៊ើបសួរទាំងនេះបានបញ្ជាក់ថា ខៀវ សារិន មិនអាចទាក់ទងបានទេ ហើយ យាយ ខឿន ទំនងជាស្លាប់ហើយ[25]។ ហេតុនេះមិនមានភ័ស្តុតាងសំខាន់ថ្មីដែល ក.ស.ច.ស ប្រមូលបានទេទាក់ទងនឹងសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ របស់ ស.ព.អ។

២៤. សំណើក្រាំងតាចាន់ គ្រាន់តែស្នើសុំដាក់ចូលក្នុងសំណុំរឿង ០០៤ នូវឯកសារដែលត្រូវភ្ជាប់ជាមួយនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងដែលមាននៅក្នុងសំណុំរឿងរួចហើយ

---

[22]សំណុំរឿង ០០៤ ឯកសារ D364/2 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ប្រតិចារឹកទាំងស្រុងចូលក្នុងសំណុំរឿង* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ កថាខណ្ឌ ១២។

[23]សំណុំរឿង ០០៤ ឯកសារ D219/994 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧។

[24]សំណុំរឿង ០០៤ ឯកសារ D338/3 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបញ្ជាក់អំពីដីកាសម្រេចលើកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ កថាខណ្ឌ ៨-១១។

[25]សំណុំរឿង ០០៤ ឯកសារ D219/995 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧។

01530433



តែប៉ុណ្ណោះ។ សំណើសុំសក្ខីកម្មសំណុំរឿង ០០២ គ្រាន់តែស្នើសុំដាក់ចូលក្នុងសំណុំរឿង ០០៤ នូវឯកសារដែលត្រូវបង្កប់សក្ខីកម្មពីសាក្សីសំណុំរឿង ០០២ ដែលមាននៅក្នុងសំណុំរឿងរួចហើយតែប៉ុណ្ណោះ។ យើងមិនយល់ឃើញថា ការដាក់ឯកសារទាំងនេះចូលក្នុងសំណុំរឿង យោងតាមដីកាសម្រេចដែល ស.ច.ស.អន្តរជាតិ បានចេញលើសំណើទាំងនេះ តម្រូវឱ្យបើកការស៊ើបសួរឡើងវិញទេ។

២៥. មិនមានការបំពេញកិច្ចស៊ើបសួរផ្សេងទៀតជាការឆ្លើយតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ ឬទី ២ របស់ ស.ព.អ ឬសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី ទេ។

២៦. ដោយផ្អែកលើមូលដ្ឋាននេះ យើងមិនយល់ឃើញថា មានកាលៈទេសៈពិសេសដែលតម្រូវឱ្យបើកការស៊ើបសួរឡើងវិញបន្ទាប់ពីដាក់សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរនេះទេ។

**តាមសំអាងហេតុខាងលើ យើង**[26]៖

២៧. **ជូនដំណឹង** ភាគី ថា យើងយល់ឃើញថា កិច្ចស៊ើបសួរលើ យឹម ទិត្យ បានបញ្ចប់ហើយ។

២៨. **ជូនដំណឹង** ភាគីថា តាមវិធានផ្ទៃក្នុង មិនតម្រូវឱ្យទុកពេលសម្រាប់កិច្ចស៊ើបសួរបន្ថែមទៀតទេ ហេតុនេះ មិនផ្តល់ជូនពេលវេលាបន្ថែមទៀតទេ។

ភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juge d'instruction

**ចៅក្រម យូ ប៊ុនឡេង ចៅក្រម** Michael BOHLANDER

---

[26]ស.ច.ស ចេញសេចក្តីជូនដំណឹងនេះរួមគ្នា ប៉ុន្តែ ដើម្បីទុកជាកំណត់ហេតុ ស.ច.ស ជាតិ សូមកត់សម្គាល់ថា ឯកសារនានាដែលបានដាក់ចូលក្នុងសំណុំរឿង០០៤ ត្រូវដាក់លេខបន្តពីឯកសារចុងក្រោយ ដែលបានដាក់មុនពេលចៅក្រម Siegfried Blunk លាលែងតំណែង ដោយមិនរាប់បញ្ចូលដីកា និងដីកាសម្រេចនានាដែលចេញដោយ ស.ច.ស បម្រុង Laurent Kasper-Ansermet ឡើយ។